World Customs Organization

# អនុស្សរណៈនៃការយោគយល់គ្នា
# រវាង

# អង្គការគយពិភពលោក
# និង
# អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

# ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលប្រចាំតំបន់របស់អង្គការគយពិភពលោក

# នៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

អនុស្សរណៈនៃការយោគយល់គ្នា (MoU) នេះត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែមិថុនាឆ្នាំ២០២៤ រវាងអង្គការគយពិភពលោក ដែលតទៅនេះ ហៅកាត់ថា "WCO" អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តទៅនេះហៅកាត់ថា "អគរ" ហៅដោយឡែកពីគ្នាថា "ភាគី" ហើយហៅរួមគ្នាថា "គូភាគី"៖

**ដោយទទួលស្គាល់នូវ** បញ្ហាប្រឈមជាច្រើនដែលកំពុងកើតឡើងចំពោះរដ្ឋបាលគយដោយសារតែការកើនឡើងនៃទំហំពាណិជ្ជកម្ម សាកលភាវូបនីយកម្មពាណិជ្ជកម្ម និងសមាហរណកម្មក្នុងតំបន់

**ដោយទទួលស្គាល់** ការកើនឡើងនៃការប្រើប្រាស់ និងលទ្ធភាពទទួលបានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានថ្មី

**ដោយទទួលស្គាល់** សារៈសំខាន់នៃការយល់ដឹងកាន់តែខ្ពស់អំពីតម្រូវការសម្រាប់រដ្ឋបាលគយក្នុងការដើរតួនាទីកាន់តែសំខាន់ក្នុងការការពារសង្គមពីការគំរាមកំហែងនានាចំពោះសន្តិសុខជាតិ

**ដោយទទួលស្គាល់ថា** ការផ្លាស់ប្តូរគំរូពាណិជ្ជកម្ម តម្រូវការបន្ថែមសម្រាប់កិច្ចសម្រួលពាណិជ្ជកម្មដោយយុត្តិធម៌ ទន្ទឹមនឹងការគាំទ្រដល់សុខភាព និងសុវត្ថិភាពប្រជាពលរដ្ឋនិងការពារសន្តិសុខជាតិ ទាមទារឱ្យមានការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋបាលគយ និងជាមួយ WCO

**ដោយទទួលស្គាល់ថា** កិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអន្តរជាតិ ផ្តល់នូវក្របខ័ណ្ឌដ៏មានសារៈប្រយោជន៍សម្រាប់ការលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលគយ

**ដោយទទួលស្គាល់ថា** ការចែកចាយព័ត៌មាន ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេស មិនអាចខ្វះបានសម្រាប់ការអនុវត្តដូចគ្នានៃការងារគយជាគន្លឹះពាក់ព័ន្ធនឹងអនុសញ្ញាអន្តរជាតិ អនុសាសន៍ និងបមាណីយកម្មផ្សេងទៀត

**ដោយទទួលស្គាល់ថា** WCO ផ្តល់នូវការបណ្តុះបណ្តាលដែលមានសារៈសំខាន់ និងពាក់ព័ន្ធ និងផ្តល់ជំនួយបច្ចេកទេសដល់សមាជិករបស់ខ្លួន

**ដោយទទួលស្គាល់** ពីតួនាទី និងសក្តានុពលដ៏មានសារៈសំខាន់របស់ អគរ ដើម្បីគាំទ្រ WCO ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការផ្តល់ជំនួយដល់សមាជិក WCO ។

បានឯកភាពដូចខាងក្រោម៖

## មាត្រា ១

## គោលបំណង និងគោលការណ៍

១. ភាគីទាំងពីរនឹងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលប្រចាំតំបន់របស់ WCO មួយ ដែលតទៅនេះហៅថា សាលាជាតិគយ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

២. WCO នឹងប្រើប្រាស់បរិក្ខារនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលនេះសម្រាប់គោលបំណងនៃការបណ្តុះបណ្តាល កិច្ចប្រជុំជំនួយបច្ចេកទេស និងព្រឹត្តិការណ៍ផ្សេងៗទាក់ទងនឹងគយក្នុងតំបន់។

## មាត្រា ២

## វិស័យសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

១. ដើម្បីសម្រេចបាននូវគោលបំណងដែលមានចែងក្នុងមាត្រា១ អគរ នឹងដាក់ឱ្យប្រើប្រាស់មជ្ឈមណ្ឌលបណ្តុះបណ្តាល WCO ដែលមានទីតាំងនៅទីក្រុងភ្នំពេញ ព្រះរាជា-ណាចក្រកម្ពុជា។

២. អគរ នឹងបន្តដំណើរការមជ្ឈមណ្ឌលបណ្តុះបណ្តាលនេះ និងប្រើប្រាស់សម្រាប់កម្មវិធីជាតិ និងអន្តរជាតិរបស់ខ្លួន។

## មាត្រា ៣

## អង្គភាពប្រតិបត្តិ

អគរ កំណត់យកសាលាជាតិគយជាអង្គភាពប្រតិបត្តិដែលទទួលខុសត្រូវក្នុងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានេះ។

## មាត្រា ៤

## ការអនុវត្ត

១. ភាគីទាំងពីរនឹងទំនាក់ទំនងគ្នាទៅវិញទៅមកអំពីផែនការបណ្តុះបណ្តាលរបស់ខ្លួន ដើម្បីកំណត់ការប្រើប្រាស់បរិក្ខាររបស់មជ្ឈមណ្ឌលបណ្តុះបណ្តាល។ WCO គួរផ្តល់ការជូនដំណឹងជាមុនយ៉ាងតិច ២ (ពីរ) ខែ មុនពេលព្រឹត្តិការណ៍ដែលបានគ្រោងទុកនីមួយៗ រួមជាមួយនឹងព័ត៌មានចាំបាច់ដើម្បីបញ្ជាក់ពីការរៀបចំព្រឹត្តិការណ៍។

២. ក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ ភាគីទាំងពីរនឹងចាត់តាំងមន្ត្រីទំនាក់ទំនងដើម្បីសម្របសម្រួលការងារនានាដែលកើតចេញពីការអនុវត្តរបស់ខ្លួន។

## មាត្រា ៥

## លក្ខខណ្ឌបច្ចេកទេសសម្រាប់ការប្រើប្រាស់មជ្ឈមណ្ឌលបណ្តុះបណ្តាល

អគរ នឹងរៀបចំឱ្យមានថ្នាក់រៀន និងអន្តេវាសិកដ្ឋាន ដោយផ្តល់នូវសម្ភារបណ្តុះបណ្តាល បន្ទប់ប្រជុំ និងសម្ភារបរិក្ខារការងារផ្សេងទៀតរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលសម្រាប់ WCO ប្រើប្រាស់។

## មាត្រា ៦

## កាតព្វកិច្ចហិរញ្ញវត្ថុ

ដើម្បីសម្រួលដល់ការអនុវត្តកម្មវិធី ឬសកម្មភាពនៃអនុស្សរណៈនៃការយោគយល់គ្នានេះ គូភាគីត្រូវទទួលខុសត្រូវក្នុងការផ្តល់ហិរញ្ញប្បទានដល់ការអនុវត្តកម្មវិធី ឬសកម្មភាពនានា នៃអនុស្សរណៈនៃការយោគយល់គ្នានេះ។

## មាត្រា ៧

## ការដោះស្រាយវិវាទ

ភាពខុសគ្នា ឬវិវាទដែលអាចកើតមានឡើងលើការបកស្រាយ ឬការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានេះ នឹងត្រូវដោះស្រាយដោយការយោគយល់គ្នាតាមរយៈការចរចាដោយផ្ទាល់ ឬការពិគ្រោះយោបល់រវាងគូភាគី។

## មាត្រា ៨

## ការកែសម្រួល

អនុស្សរណៈនៃការយោគយល់គ្នានេះអាចត្រូវបានពិនិត្យឡើងវិញ ឬកែសម្រួលនៅពេលណាមួយតាមរយៈការពិគ្រោះយោបល់គ្នាទៅវិញទៅមក និងការយល់ព្រមជាលាយលក្ខណ៍អក្សរដោយគូភាគី។ ការត្រួតពិនិត្យឡើងវិញ ឬកែសម្រួលនេះត្រូវចូលជាធរមាននៅកាលបរិច្ឆេទដែលបានកំណត់ដោយគូភាគី ហើយត្រូវបង្កើតជាផ្នែកសំខាន់មួយនៃអនុស្សរណៈនៃការយោគយល់គ្នានេះ។

## មាត្រា ៩

## ការចូលជាធរមាន រយៈពេល និងការបញ្ចប់

១. អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

២. អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវនៅជាធរមានសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ហើយអាចបន្តសុពលភាពដោយមានការយល់ព្រមពីគូភាគី។

៣. ការបញ្ចប់អនុស្សរណៈនៃការយោគយល់គ្នានេះនឹងមិនប៉ះពាល់ដល់សុពលភាព និងរយៈពេលនៃកម្មវិធី ឬសកម្មភាពកំពុងដំណើរការ ដែលកើតឡើងមុនការបញ្ចប់អនុស្សរណៈនៃការយោគយល់គ្នានេះឡើយ។

ធ្វើនៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤ ជា ៤ (បួន) ច្បាប់ដើម ក្នុងនោះ ជាភាសាអង់គ្លេស ចំនួន ២ (ពីរ) ច្បាប់ និងភាសាខ្មែរ ចំនួន ២ (ពីរ) ច្បាប់ អត្ថបទទាំងអស់មានតម្លៃស្មើៗគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

តំណាងអង្គការគយពិភពលោក

**លោក Ian SAUDERS**
**អគ្គលេខាធិការ**
**អង្គការគយពិភពលោក**

តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**បណ្ឌិត គុណ ញឹម**
**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុ**